PPCBank

# របាយការណ៍ប្រចាំត្រីមាសទី១

(ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.០៨៥.៥២៨ | ៤.០១៥.០៤១ |
| បំណុលសរុប | ៣.៣៥៣.៨២៦ | ៣.៣០៦.៨១៧ |
| មូលធនសរុប | ៧៣១.៧០២ | ៧០៨.២២៤ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ត្រីមាសទី១ ឆ្នាំ២០២១** |
| ចំណូលសរុប | ៧៨.៦១០ | ៧៦.៩០៨ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ៣៤.៦៧៧ | ១៧.១៥៥ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ២៧.៧៣៩ | ១៣.៦០៦ |
| លទ្ធផលម្អិតក្នុងការិយបរិច្ឆេទ | ២៥.៩២៦ | ១៣.៥៦១ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព ❶ | ១៩,២២ | ១៩,១៩ |
| អនុបាតបំណុលធៀបនឹងមូលធន | ៤៥៨,៣៦ | ៤៦៦,៩២ |
| អនុបាតគ្របខ័ណ្ឌសន្ទនីយភាព ❶ | ១២៣,៤៨ | ១២៥,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៣,៦៤ | ១,៨២ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៥,៦១ | ៩៧,០៨ |
| **អនុបាតផលចំណេញ (%)** | **ត្រីមាសទី១ ឆ្នាំ២០២២** | **ត្រីមាសទី១ ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) | ២,៥៧ | ១,៣០ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) | ១៤,៣៧ | ៨,៥៥ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៩៦៥,២៦ | ៦៤០,៣៧ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶ : អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷ : ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

សមាជិក



**Kim, Sung Chul**

សមាជិក



**PARK, Chong Tae**

សមាជិកឯករាជ្យ



**LEE, Myunsang**

សមាជិកឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ដោយអនុវត្តតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ដូចដែលយើងទាំងអស់គ្នាបានជ្រាបរួចមកហើយថា ការឆ្លងនៃមេរោគ កូវីដ-១៩ មានការថយចុះ រាជរដ្ឋាភិបាលបានប្រកាសបើកប្រទេសឡើងវិញទាំងស្រុងលើគ្រប់វិស័យ ដើម្បីស្តារសេដ្ឋកិច្ចជាតិឡើងវិញបន្ទាប់ពីរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយមេរោគរាតត្បាត កូវីដ-១៩ ក៏ដូចជាការប្រកាសបិទបញ្ចប់ព្រឹត្តការណ៍នៃការឆ្លងមេរោគ កូវីដ-១៩ ក្នុងសហគមន៍ ២០ កុម្ភៈ ផងដែរ។ ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគ កូវីដ-១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បាននិងកំពុងខិតខំប្រឹងប្រែងក្នុងការស្វែងរក វ៉ាក់សាំងកូវីដ-១៩ ដើម្បីការពារប្រជាជនពីមេរោគដ៏កាចសាហាវមួយនេះ, កាត់បន្ថយការសម្រាកព្យាបាល នៅមន្ទីរពេទ្យ, ការជួយសង្គ្រោះជីវិតមនុស្ស និងការជួយស្តារសេដ្ឋកិច្ចប្រទេសជាតិឲ្យបាន ល្អប្រសើរឡើង។

ទោះបីករណីកូវីដ-១៩ មិនទាន់បានបញ្ចប់ទាំងស្រុងក៏ដោយ ក៏ក្នុងក្នុងត្រីមាសទី១ ឆ្នាំ២០២២ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមដំណើរការជាផ្លូវការនូវសេវាបង់ភាគទានបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដែលអនុញ្ញាតឲ្យអតិថិជន (ក្រុមហ៊ុន រោងចក្រ សហគ្រាស នានា) អាចធ្វើការបង់សេវាបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ប្រចាំខែតាមរយៈបណ្តាញផ្សេងៗ ដូចជាតាមសេវាធនាគារចល័ត (PPCBank Mobile App), សេវាធនាគារតាមប្រព័ន្ធអ៊ីនធើណែត (Corporate Internet Banking) ដែលយើងហៅថា smartBiz និងតាមបញ្ជរសាខាធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ ជាមួយគ្នានេះដែរ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏បានធ្វើបច្ចុប្បន្នភាពមុខងារថ្មីនៅលើ PPCBank Mobile App ដែលអនុញ្ញាតឱ្យអតិថិជនប័ណ្ណឥណទាន PPCBank បង់វិក្កយបត្រប័ណ្ណឥណទានរបស់ពួកគេ នៅលើកម្មវិធីសេវាធនាគារចល័តរបស់ PPCBank បាន។ បន្ថែមពីនេះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏ទទួលបាននូវការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា ក្នុងការប្រកបអាជីវកម្ម បែងកាសួរនេម៉ូឌែលណែនាំអតិថិជន (Referral) របស់ក្រុមហ៊ុន ព្រូដិនសល

(ខេមបូឌា) ឡាយហ្វ៍ អ៊ីស្សូរ៉ិនស៍ ម.ក លើផលិតផលធានារ៉ាប់រងអាយុជីវិត ក៏ដូចជាការអនុញ្ញាតផ្សេងៗទៀតពី ធនាគារជាតិ នៃ កម្ពុជា អំពីតែងតាំងនាយក/នាយិកាសាខារបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ផងដែរ។

គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២២ កំណើននៃទ្រព្យសកម្មរបស់យើងមានការកើនឡើងប្រហែល ២,៤% គឺកើនឡើងពី ៩៨៦ លានដុល្លារអាមេរិក ទៅ ១.០០៩ លានដុល្លារអាមេរិក, ឥណទានមានការកើន ១,៩% ពីចំនួន ៧៤៦ លានដុល្លារអាមេរិក ទៅ ៧៦០ លានដុល្លារអាមេរិក, ប្រាក់បញ្ញើ មានការកើនឡើង ៣,៤% ពី ៧៤៤ លានដុល្លារអាមេរិក ទៅ ៧៧០ លានដុល្លារអាមេរិក និងមូលធនមានការកើនឡើង ៣,៩% ពី ១៧៤ លានដុល្លារអាមេរិក ទៅ ១៨១ លានដុល្លារអាមេរិក។ នេះគឺជាកំណើននៅក្នុងត្រីមាសទី៤ ឆ្នាំ២០២១ ប្រៀបធៀបជាមួយត្រីមាសទី១ ឆ្នាំ២០២២។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ, បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្ត និង អតិថិជនរបស់យើងទាំងអស់សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលបត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ។

ខ្ញុំ Yim Yong Taick សូមសម្តែងនូវការដឹងគុណចំពោះការខិតខំប្រឹងប្រែង ដោយទទួលបានលទ្ធផលជោគជ័យក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០២២ និងបន្តឆ្ពោះទៅរកសមិទ្ធិផលដ៏ល្អប្រសើរបន្ថែមទៀតក្នុងត្រីមាសទី២ ឆ្នាំ២០២២។

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

ហត្ថលេខា និងត្រា

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 1

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 2

**សមាសភាពក្រុមប្រឹក្សាភិបាល** ........ 3

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........ 4

**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 7

ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 7

ខ. លក្ខណៈនៃធុរកិច្ច ........ 8

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ 9

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ 10

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ........ 10

ខ. រចនាសម្ព័ន្ធចំណូល ........ 10

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ........ 11

**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........ 12

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 12

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ 14

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ 16

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ 16

ង. ផលប៉ះពាល់អតិផរណា ........ 17

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ........ 17

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** ........ 17

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Baek Jongil |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្តើមប្រតិបត្តិការធនាគារនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំ គឺ Jeonbuk Bank Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.), ក្រុមហ៊ុន Apro Financial Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co., Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co., Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co., Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀត យើងក៏មិនភ្លេចនឹងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្រ្តនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ខែមីនា ឆ្នាំ២០២២ ទ្រព្យសកម្មសរុបមានចំនួន ១.០០៩ លានដុល្លារអាមេរិក និងធ្វើការបម្រើអតិថិជនច្រើនជាង ១៣២.០០០ នាក់ ជាមួយនឹងសាខាចំនួន២៣ទូទាំងប្រទេស និងម៉ាស៊ីនATMs ចំនួន៧០ (ម៉ាស៊ីន ATMsផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្តានុពលផ្សេងៗទៀតក្នុងប្រទេសកម្ពុជា)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តធ្វើការផ្តល់ ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថល ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួលជាមួយនឹងបទពិសោធន៍ធនាគារ។ អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ Live Chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្តល់នូវផលិតផល និងសេវាSME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាន

នូវសេវាពិគ្រោះយោបល់អាជីវកម្មផងដែរ។ ពួកយើង ក៏បានពង្រីកនូវការិយាល័យបរទេស (Foreign Desk) មានដូចជា ការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផល-សេវារបស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ដើម្បីអនុលោមតាមប្រកាសរបស់ ធនាគារជាតិ នៃ កម្ពុជាលេខ ធ៧-០២១-១០៥ ប្រ.ក ស្តីពីលក្ខខណ្ឌសម្រាប់គ្រឹះ ស្ថានធនាគារ និងហិរញ្ញវត្ថុ និងលិខិតលេខ ធ៧-០២១-៦០២ ឆ.ត ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានដាក់លិខិតស្នើសុំ និងទទួលបានការអនុញ្ញាតពីធនាគារជាតិ នៃ កម្ពុជា កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ក្នុងការប្រកបអាជីវកម្មប្រែងកាសួរេនម៉ូឌែលណែនាំអតិថិជន (Referral) របស់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺស្សួរ៉ិនស៍ ម.ក លើផលិតផលធានារ៉ាប់រងអាយុជីវិត សម្រាប់ការិយាល័យចំនួន ០៥ ដែលរួមមាន ទីស្នាក់ការកណ្តាល សាខាបឹងត្របែក សាខាអូរឫស្សី សាខាសែនសុខ និងសាខាម៉ៅសេទុង។

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏បានចាប់ផ្តើមដំណើរការជាផ្លូវការនូវសេវាបង់ភាគទានបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដែលអនុញ្ញាតឲ្យអតិថិជន អាចធ្វើការបង់សេវាបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ប្រចាំខែរបស់ពួកគេ តាមរយៈបណ្តាញផ្សេងៗដូចជា តាមសេវាធនាគារចល័ត (PPCBank Mobile App), សេវាធនាគារតាមប្រព័ន្ធអ៊ីនធើណែត (smartBiz) និងតាមបញ្ជរសាខាធនាគារភ្នំពេញ ពាណិជ្ជ ម.ក ចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក៏បានធ្វើបច្ចុប្បន្នភាពមុខងារថ្មីនៅលើ PPCBank Mobile App ដែលអនុញ្ញាតឱ្យអតិថិជនប័ណ្ណឥណទាន PPCBank បង់វិក្កយបត្រប័ណ្ណឥណទានរបស់ពួកគេនៅលើកម្មវិធីសេវាធនាគារចល័តរបស់ PPCBank បាន។ អតិថិជនប័ណ្ណឥណទានអាចបង់ចំនួនដែលនៅសេសសល់ នៅពេលដែលមានរបាយការណ៍ចេញវិក្កយបត្រប័ណ្ណឥណទាន។ ការទូទាត់មានចំនួន ០៣ប្រភេទ ដែលអតិថិជនអាចបង់បានដូចជា ការទូទាត់ពេញ ការទូទាត់អប្បបរមា និងចំនួនផ្សេងទៀត (ចាប់ពីអប្បបរមារហូតដល់ចំនួនពេញ)។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី១ ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៧.៥១១ | ៧.៣០៨ |
| ឥណទានដុលសរុប (លានរៀល) | ៣.០៧៨.០៧១ | ៣.០៣៧.៩៣១ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៦១.៥៦១ | ១៥៨.៥៦១ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ៣.១១៧.២៤២ | ៣.០៣២.៥៥៦ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៥២ | ៤៤៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៦៨ |
| ចំនួនម៉ាស៊ីនទូទាត់ | ២៥៤ | ២៣៨ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៦.១៤៣ | ៩៦,៨៦ | ៧២.៦៥៧ | ៩៤,៤៧ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.៤៤៥ | ៣,១១ | ៣.០៣០ | ៣,៩៤ |
| ៣ | ចំណូលផ្សេងៗ | ២២ | ០,០៣ | ១.២២១ | ១,៥៩ |
| **ចំណូលសរុប** | | **៧៨.៦១០** | **១០០** | **៧៦.៩០៨** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ម.ក (PPCBank) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co., Ltd គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជ ម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២២ | | ត្រីមាសទី១ ឆ្នាំ២០២១ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៧៦.១៤៣ | ៩៦,៨៦ | ៧២.៦៥៧ | ៩៤,៤៧ |
| ២ | ចំណូលកម្រៃ និងជើងសារ | ២.៤៤៥ | ៣,១១ | ៣.០៣០ | ៣,៩៤ |
| ៣ | ចំណូលផ្សេងៗ | ២២ | ០,០៣ | ១.២២១ | ១,៥៩ |
| ចំណូលសរុប | | ៧៨.៦១០ | ១០០ | ៧៦.៩០៨ | ១០០ |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៧% នៃប្រាក់ចំណូល សរុបក្នុងត្រីមាសទី១ ឆ្នាំ២០២២។

## ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុប ដកនឹងចំណាយការប្រាក់ ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគ ចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៏ចំនេញខាត | ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៧៦.១៤៣ | ៧២.៦៥៧ | ២.០៨៤ | ២,៨៧ |
| ចំណាយលើការប្រាក់ | (២៣.៨១៣) | (២៩.៥៥៣) | ៥.៧៤០ | (១៩,៤២) |
| **ចំណូលមកពីការប្រាក់សុទ្ធ** | **៥២.៣៣០** | **៤៣.១០៤** | **៧.៨២៤** | **១៨,១៥** |
| ចំណូលកម្រៃ និងជើងសារ | ២.៤៤៥ | ៣.០៣០ | ៨១៨ | ២៧,០១ |
| ចំណាយកម្រៃ និងជើងសារ | (៩៤៥) | (១.០៦៣) | ១១៨ | (១១,០៨) |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | **១.៥០០** | **១.៩៦៧** | **៩៣៦** | **៤៧,៦០** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២២ | ១.២២១ | (១.២០០) | (៩៨,២៣) |
| ចំណាយបុគ្គលិក | (៦.៧៦៥) | (៧.៤៦៥) | ៧០០ | (៩,៣៨) |
| ចំណាយប្រតិបត្តិការ | (៣.៩៥៩) | (៦.៧៣១) | ២.៧៧៣ | (៤១,១៩) |
| ចំណាយរំលស់ | (៦.៧៧០) | (៧.៦៥៧) | ៨៨៧ | (១១,៥៨) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៣៦.៣៥៩** | **២៤.៤៣៩** | **១១.៩២០** | **៤៨,៧៧** |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (១.៦៨២) | (៧.២៨៤) | ៥.៦០២ | (៧៦,៩១) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៣៤.៦៧៧** | **១៧.១៥៥** | **១៧.៥២២** | **១០២,១៤** |

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ៣៤.៦៧៧លានរៀល (១០២% កើនឡើងប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២១) ។ ការកើនឡើងនៃប្រាក់ចំណេញភាគច្រើនគឺទទួលបានមកពីការកើនឡើងនៃចំណូលដែលទទួលបានពីការផ្តល់ឥណទានដល់អតិថិជន និងការថយចុះនៃចំណាយការប្រាក់។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៏ចំណេញខាត | ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣៤.៦៧៧ | ១៧.១៥៥ | ១៧.៥២២ | ១០២,១៤ |
| ចំណាយពន្ធលើប្រាក់ចំណូល | (៦.៩៣៨) | (៣.៥៤៩) | (៣.៣៨៩) | ៩៥,៤៩ |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **២៧.៧៣៩** | **១៣.៦០៦** | **១៤.១៣៣** | **១០៣,៨៧** |

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ២៧.៧៣៩លានរៀល ដែលបានកើនឡើង ១០៤% ប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២១ មូលហេតុនៃការកើនឡើងនេះ ដូចដែលបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៏ចំណេញខាត | ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២១ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ២៧.៧៣៩ | ១៣.៦០៦ | ១៤.១៣៣ | ១០៣,៨៧ |
| ការខាតលម្អិតផ្សេងៗ | (១.៨១៣) | (៤៥) | (១.៧៦៨) | ៣.៩៥២,២៩ |
| **ប្រាក់ចំណេញលម្អិតសរុប** | **២៥.៩២៦** | **១៣.៥៦១** | **១២.៣៦៥** | **៩១,១៧** |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ផលប៉ះពាល់ពីមេរោគ កូវីដ-១៩ នៅមិនទាន់ចប់នៅឡើយទេ រួមទាំងបញ្ហាជម្លោះរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន នឹងមានផលប៉ះពាល់ដល់សេដ្ឋកិច្ចសកលតាមរយៈបណ្តាញសំខាន់ៗចំនួនបី៖ ទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ តម្លៃទំនិញ និងការរំខានដល់ខ្សែសង្វាក់នៃការផ្គត់ផ្គង់។ ជាមួយនឹងវិធានការបិទខ្ទប់ថ្មីៗនេះនៃមេរោគ កូវីដ-១៩ នៅក្នុងប្រទេសចិន ក៏កំពុងមានផលរំខានដល់ខ្សែសង្វាក់ពាណិជ្ជកម្មតាមសមុទ្រផងដែរ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគ្រប់គ្រងយល់ឃើញថា សកម្មភាពរបស់ក្រុម និងធនាគារ អាចមានភាពយឺតយ៉ាវក្នុងរយៈពេលខ្លី ប៉ុន្តែនឹងមិននាំឱ្យមានបញ្ហាដែលគួរឱ្យកត់សំគាល់នោះទេ ដោយសារតែទំហំនៃប្រតិបត្តិការ កម្រិតប្រាក់ចំណេញបច្ចុប្បន្ន និងលំហូរសាច់ប្រាក់ងាយស្រួលរបស់ក្រុម និងធនាគារ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ជាមួយនឹងតម្លៃប្រេងឥន្ធនៈនាពេលបច្ចុប្បន្នបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ក៏ដូចជាការបិទខ្ទប់ចំពោះមេរោគ កូវីដ-១៩ នាពេលថ្មីៗនេះ នៅក្នុងប្រទេសចិន ក៏កំពុងរំខានដល់ពាណិជ្ជកម្មតាមសមុទ្រផងដែរ ដែលនេះអាចនាំឱ្យមានកង្វះខាតវត្ថុធាតុដើមថ្មី ដែលអាចប៉ះពាល់ដល់តម្រូវការ និងខ្សែសង្វាក់ផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដូច្នេះដើម្បីរក្សាឲ្យបាននូវកំណើននៃប្រាក់ចំណេញ និងគុណភាពទ្រព្យសកម្ម ដើម្បីធានាបាននូវកំណើនប្រកបដោយនិរន្តរភាពការទទួលបានមូលនិធិថ្មីៗ ដែលមានការចំណាយថ្លៃដើមទាប និងកំណើននៃប្រាក់កម្ចី SME នៅតែជាកត្តាចំបងបំផុត។ ដើម្បីសម្រេចបាននូវលទ្ធផលនេះ ធនាគារនៅតែកំពុងបន្តអភិវឌ្ឍន៍ប្រព័ន្ធឌីជីថលរបស់ធនាគារ និងការសហការភាពជាដៃគូបន្ថែមទៀតជាមួយស្ថាប័នផ្សេងៗដូចខាងក្រោម៖

- ធនាគារ PPCBank បានដាក់ឱ្យដំណើរការជាផ្លូវការនូវសេវាបង់ថ្លៃសេវារបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលអនុញ្ញាតឱ្យអតិថិជនបង់ថ្លៃសេវាប្រចាំខែរបស់ ប.ស.ស តាមរយៈបណ្តាញផ្សេងៗដូចជា Mobile App, smartBiz និងសេវានៅបញ្ជរផ្ទាល់។

- ធនាគារ PPCBank បានធ្វើឱ្យប្រសើរឡើងនូវមុខងារថ្មីនៅលើ Mobile App ដែលអនុញ្ញាតឱ្យអ្នកកាន់ប័ណ្ណឥណទាន PPCBank អាចបង់វិក្កយបត្រប័ណ្ណឥណទានរបស់ពួកគេនៅលើកម្មវិធីទូរស័ព្ទចល័តរបស់ PPCBank បានដោយផ្ទាល់។ អ្នកកាន់ប័ណ្ណឥណទានអាចបង់សមតុល្យឥណទានដែលបានប្រើនៅលើប័ណ្ណឥណទាន នៅពេលដែលរបាយការណ៍វិក្កយបត្រនៃប័ណ្ណឥណទានបានបង្ហាញលើ PPCBank Mobile App របស់ពួកគេ។ មាន៣ប្រភេទនៃការទូទាត់ ដែលអតិថិជនអាចបង់បានដូចជា ការទូទាត់សមតុល្យពេញទាំងអស់ ការទូទាត់អប្បបរមា និងការទូទាត់ចំនួនផ្សេងទៀត (ចាប់ពីចំនួនសមតុល្យអប្បបរមារហូតដល់ចំនួនសមតុល្យពេញ)។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

### ៣. ការវិភាគលើពន្ធ

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ស្ថានភាពសេដ្ឋកិច្ចដែលរងផលប៉ះពាល់ដោយជម្លោះរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន រួមទាំងការបិទខ្ទប់ថ្មីចំពោះស្ថានភាពនៃមេរោគ កូវីដ-១៩ នៅក្នុងប្រទេសចិននាពេលថ្មីៗនេះ អាចមានផលប៉ះពាល់ខ្លះៗដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ធនាគារភ្នំពេញពាណិជ្ជ មានការកើនឡើងនៃចំណូល ដែលមានចំណូលការប្រាក់សុទ្ធសរុប ៥០.៩២៨លានរៀល ដែលស្មើនឹងការកើនឡើង ១៨,២% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២១។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញាត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

មិនមានផលប៉ះពាល់ណាមួយជាសារវន្ត នៃអតិផរណាមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

យោងតាមការជូនដំណឹងពីអគ្គនាយកដ្ឋានពន្ធដារ (GDT) ការអនុវត្តពន្ធលើចំណេញមូលធននឹងពន្យារពេលដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤។ ការសម្រេចនេះគឺដើម្បីគាំទ្រដល់ចក្ខុវិស័យថ្មីរបស់រាជរដ្ឋាភិបាលក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការវិនិយោគ បន្ទាប់ពីការរាតត្បាតនៃមេរោគ កូវីដ-១៩ តាមរយៈការចូលរួមអនុវត្ត "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងបរិបទនៃការរស់នៅជាមួយ កូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣"។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

បានអាន និងឯកភាព

លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank